ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប
លេខ ០១៣/១៧ អលខ.

**គោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**កម្មវត្ថុៈ** គោរពជូនរបាយការណ៍សរុប កិច្ចប្រជុំពិភាក្សា **"ស្តីពីបទអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ"** ចំនួន ០៤លើក ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

- លើកទី១ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦
- លើកទី២ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦
- លើកទី៣ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦
- លើកទី៤ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦

ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានការអញ្ជើញចូលរួមពីបណ្តាក្រសួង ស្ថាប័ន តំណាងស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា និងអង្គការពាក់ព័ន្ធមួយចំនួន។

សេចក្តីដូចបានគោរពជម្រាបជូនតាមកម្មវត្ថុខាងលើ លេខាធិការដ្ឋានរដ្ឋបាលសរុប សូមជូនរបាយការណ៍អំពីលទ្ធផលកិច្ចប្រជុំពិភាក្សាទាំង០៤លើកដូចខាងក្រោមៈ

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងមកមានសកម្មភាពបង្ក្រាបបទល្មើស **អន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ** ដោយចាប់បានជនសង្ស័យឈ្មោះ CHARLES TAMMY LAYNE ហៅ TAMMY ភេទស្រី អាយុ៤៩ឆ្នាំ ជនជាតិអូស្ត្រាលី ដែលជាអ្នកជួលស្ត្រីខ្មែរឲ្យពពោះបង្កើតកូនចំនួន ២៣នាក់ និងបាននាំយកចេញទៅក្រៅប្រទេសចំនួន ០៦នាក់ ក្នុងនោះមានកូនភ្លោះចំនួន ០២នាក់ ដោយទទួលបានតម្លៃខ្លួនពីគ្រួសារចង់បានកូនម្នាក់ចំនួន ៥០,០០០ ដុល្លារ(ប្រាំម៉ឺនដុល្លារសហរដ្ឋអាមេរិកគត់) ហើយនៅមានស្ត្រីចំនួន ១៨នាក់ ទៀតកំពុងពពោះដោយពុំបានចេញមកបង្ហាញខ្លួនឡើយ។

## I.ការងារសម្របសម្រួល និងដំណោះស្រាយ

ក្រោយពីធ្វើការបង្ក្រាបករណីខាងលើនេះរួចមក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានធ្វើការកោះប្រជុំពិភាក្សារកដំណោះស្រាយ និងសម្របសម្រួល ហើយទទួលបានព័ត៌មានពីកាសែត និង វិទ្យុអូស្ត្រាលីថា មានទារកចំនួន៧០នាក់ហើយដែលត្រូវបាននាំចេញពីកម្ពុជា។ បើយោងតាមរបាយការណ៍

របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា គិតពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៦ នេះមានទារកដែលបាននាំយកចេញទៅអូស្ត្រាលី គឺមានចំនួន០៦នាក់ប៉ុណ្ណោះ។

ដើម្បីដោះស្រាយនូវបញ្ហានេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានប្រជុំពិភាក្សាលើកយកគោលការណ៍ចំនួន ០៣ចំណុច ដែលជាគំនិតផ្តួចផ្តើមរបស់ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងទទួលបានការឯកភាពពី **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ក្នុងនោះគឺ៖

**ទី១**.សុំឲ្យភាគី អូស្ត្រាលី ផ្អាកទទួលការស្នើសុំការពពោះជំនួសនេះមកអនុវត្តនៅកម្ពុជាសិន ដើម្បីកុំឲ្យកើតមានឡើងនូវករណីថ្មីទៀតក្នុងអំឡុងពេលដោះស្រាយករណីដែលមានរួចហើយ។

**ទី២**.ដោះស្រាយករណីដែលកំពុងមាននៅដៃ គឺកូនដែលកំពុងមាននៅក្នុងផ្ទៃស្ត្រីចំនួន ១៨នាក់ និងស្ត្រីមួយចំនួនទៀត ព្រមទាំងកូនដែលពុំទាន់បានយកចេញទៅ អូស្ត្រាលីនៅឡើយ។ ដោយតម្រូវឲ្យយកថវិកាដែលជនស្ម័យទទួលបានពីអ្នកចង់បានកូន មកឧបត្ថម្ភស្ត្រីកំពុងពពោះតាមការសន្យារហូតដល់កូនកើត និងសុំឲ្យភាគីអូស្ត្រាលី បញ្ជូនអ្នកដែលចង់បានកូននោះ ចេញមុខមកទទួលខុសត្រូវក្នុងការធ្វើជាឪពុក ឬម្តាយចំពោះទារកទាំងនោះ។

**ទី៣**.សុំឲ្យមានកិច្ចសហការពីប្រទេសអូស្ត្រាលី ដើម្បីរៀបចំបែងចែកបែបបទ នីតិវិធីរួមគ្នាបានសមស្រប ត្រឹមត្រូវដើម្បីដោះស្រាយចំពោះករណីដែលកើតមានរួចមកហើយ។ ចំពោះករណីថ្មី គឺត្រូវរង់ចាំការណែនាំថ្មីពីរាជរដ្ឋាភិបាល និងច្បាប់កំណត់។

ចំពោះស្ត្រីដែលកំពុងពពោះចំនួន១៨នាក់ នោះវិញ ពេលកូនបានកើតចេញមក គឺគាត់ពុំមានលទ្ធភាពយកទៅចិញ្ចឹមទេដោយពួកគាត់មានជីវភាពក្រីក្រ ហើយកូននោះពុំមែនជាកូនរបស់ពួកគាត់។ បញ្ហានេះនឹងអាចធ្លាក់ជាបន្ទុកដល់រាជរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវលើទារកនោះ។

តាមនីតិវិធី នៃការសុំកូនអន្តរប្រទេស នីតិវិធីមួយចំនួនយើងអាចទទួលយកបាន តែវាខុសគ្នាត្រង់ ទារកដែលត្រូវនាំយកចេញទៅប្រទេសគោលដៅ គឺជាកូនរបស់អ្នកស្នើសុំដោយមានការត្រួតពិនិត្យតាមរយៈ (DNA)។

## II.ការងារសំណុំបែបបទ និងនីតិវិធី

អង្គប្រជុំពិភាក្សាលើករណី "បទអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ" ចំនួន ០៤លើក កន្លងមកនេះ បានសម្រេចឯកភាពលើកយកនីតិវិធី និងបែបបទសម្រាប់អនុវត្តរួមគ្នាគឺ៖

- ឯកសាររបស់អ្នកស្នើសុំ

  -ពាក្យស្នើសុំ

  -រូបថត

  -ស្នាមក្រយ៉ៅដៃ

  -លិខិតថ្កោលទោស

  -លិខិតបញ្ជាក់អំពីសុខភាព (មន្ទីរពេទ្យរដ្ឋ)

  -ស្ថានភាពគ្រួសារ លិខិតបញ្ជាក់ទីលំនៅ ទ្រព្យសម្បត្តិ និងប្រាក់ចំណូល/ មុខរបរ

-លិខិតជានាអះអាង កិច្ចសន្យាក្នុងការចិញ្ចឹមថែទាំ

-សុពលភាពលិខិតឆ្លងដែន

-លិខិតបញ្ជាក់ DNA

-របាយការណ៍បញ្ជាក់ពីការរីកលូតលាស់របស់កុមារ

➢ **សំណុំលិខិតពីអ្នកពពោះ**

-លិខិតពេទ្យ(សម្រាលកូន)

-សបុត្រកំណើតកូន

-កិច្ចសន្យាពពោះ

-ស្ថានភាពអ្នកពពោះ

-សាលក្រមផ្ទេរសិទ្ធិអាណាព្យាបាលស្របច្បាប់ពីតុលាការ(ស្នើសុំសញ្ជាតិ)

➢ **សំណុំលិខិតរបស់ស្ថានទូត**

-កំណត់ទូត បញ្ជូនលិខិតផ្លូវការ ដោយមានប្រថាប់ត្រាលើសំណុំឯកសារ(លិខិតអ្នកស្នើសុំ)

➢ **សំណុំលិខិតអនុញ្ញាតិរបស់ស្ថាប័នពាក់ព័ន្ធ**

-ក្រសួងមហាផ្ទៃ

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ស្ថានទូតប្រទេសគោលដៅ ប្រចាំព្រះរាជាណាចក្រកម្ពុជា

➢ **នីតិវិធី និងស្ថាប័នអនុវត្ត**

កិច្ចប្រជុំពិភាក្សាបានឯកភាពគ្នាអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- រាល់សំណុំឯកសាររបស់អ្នកស្នើសុំ ត្រូវមានបញ្ជាក់ជានាអះអាងទទួលស្គាល់ ពីស្ថានទូតរបស់ខ្លួន ដែលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា រួចបញ្ជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា។
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា ត្រូវធ្វើសេចក្តីជូនដំណឹងដល់ក្រសួងមហាផ្ទៃ ដើម្បីឲ្យអគ្គនាយកដ្ឋានជំនាញធ្វើការបំពេញបែបបទ ទិដ្ឋាការចេញឲ្យអ្នកស្នើសុំ នាំយកទារកទៅប្រទេសរបស់ខ្លួនតាមផ្លូវច្បាប់។

## III.សំណូមពរ

ក្រោយពីមានការជួបប្រជុំពិភាក្សាលើករណីនេះចំនួន ០៤លើក រួចមកប្រធាន និងសមាជិក នៃអង្គប្រជុំពិភាក្សាទាំងអស់បានសម្រេចសំណូមពរដូចខាងក្រោម៖

➢ សុំឲ្យអូស្រ្តាលី ផ្អាកលើការស្នើសុំឲ្យពពោះជំនួស និងនាំយកទារកចេញទៅក្រៅប្រទេសសិន។

➢ សុំឲ្យបង្កើតជាគណៈកម្មការកណ្តាលមួយ ដើម្បីត្រួតពិនិត្យ វាយតម្លៃ លើករណីសុំពពោះជំនួស និងសុំកូនរបស់ជនបរទេសដើម្បីយកទៅចិញ្ចឹមធ្វើជាកូននៅប្រទេសគេ។

- សុំឲ្យខាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ផ្តល់ឯកសារពាក់ព័ន្ធ ទិដ្ឋាការ នៃការសុំកូន និងស្រ្តីពពោះជំនួស ឬកុមារ យកចេញទៅក្រៅប្រទេសមក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ដើម្បីសិក្សាចងក្រង វាយតម្លៃលម្អិតឲ្យបានរឹងមាំ សម្រាប់បកស្រាយជាមួយបណ្តាស្ថានទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជាយើង។
- សុំឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជួយផ្តល់ពេលវេលា ទីកន្លែង បញ្ជីឈ្មោះ របស់តំណាងស្ថានទូត ដែលត្រូវចូលរួមប្រជុំលើករណីនេះនាពេលខាងមុខ។

**IV.ទិសដៅបន្ត**

- បន្តជួបប្រជុំពិភាក្សាជាមួយអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ត្រៀមជួបប្រជុំពិភាក្សាលើករណី "បទអន្តរការ រវាងអ្នកសុំកូន និងស្រ្តីពពោះ" ជាមួយបណ្តាស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា នាពេលខាងមុខ។

សេចក្តីដូចបានគោរពពាយការណ៍ជូនខាងលើសូម **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧

**ប្រធានការិយាល័យអប់រំ ផ្សព្វផ្សាយ**

kamil

អ៊ូ - កាមិល

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍**

មេត្តាជ្រាបជារបាយការណ៍។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប

ឧត្តមសេនីយ៍ត្រី **គង់_ពុទ្ធី**

02/02/17

ជូ_ប៊ុនអេង

ឧបសម្ព័ន្ធ ៤

# សមាសភាពចូលរួមកិច្ចប្រជុំពិភាក្សា
# ស្តីពីករណីអំពើធ្វើអន្តរភាវី នៃអំពើពពោះ

សាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦

| | | |
|---|---|---|
| ១.លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃ គ.ជ.ប.ជ |
| ២.ឯ.ឧ ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.ឯ.ឧ ឧ.ឯក | ប៉ុល ភិលេយ្យ | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ៤.ឯ.ឧ ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥.ឯ.ឧ ឧ.ឯក | ខៀវ ចាន់រ៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦.ល.ជំ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៧.លោក | ហួន ទីម | អង្គការ APLE |
| ៨.លោក | MIKE NOWLIN | Executive Director ( HAGAR) |
| ៩.លោកស្រី | សេង ដាណែត | ប្រធានធនធានមនុស្ស ( HAGAR ) |
| ១០.លោកស្រី | កែវ រ៉ាវី | ប្រធានអង្គការ Children in Family |
| ១១.លោក | ខឹម រ៉ាន់ដូ | នាយកកម្មវិធី APLE |
| ១២.លោក | សំនៀង សីលា | នាយកប្រតិបត្តិ APLE |
| ១៣.លោក | អ៊ុន ច័ន្ទថុល | មេធាវី APLE |
| ១៤.លោក | ណុប រដ្ឋា | ប្រធានការិយាល័យ MFA |
| ១៥.លោក | លី សុវិច្ឆ័យ | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ១៦.លោក ឧ.ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១៧.លោក ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន កិច្ចការយុត្តិធម៌ គ.ជ.ប.ជ |
| ១៨.លោក | តែ សុថារ៉េត | អនុប្រធាននាយកដ្ឋានអនុវត្តច្បាប់ គ.ជ.ប.ជ |
| ១៩.លោក | ឈា សុវណ្ណ | ប្រធានវិទ្យាស្ថានសុខភាពសាធារណៈ |
| ២០.លោកស្រី | ជា សុម៉ាលី | ប្រធានការិយាល័យកិច្ចការគ្រួសារ ក្រសួងសង្គមកិច្ច |
| ២១.លោក វ.ឯក | កែវ ជា | ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ២២.លោក | GARY WYNCEL | AFP-SLO( Australian Federal Police |
| ២៣.លោក | Sarom Seila | AFP ( Autralia Embassy ) |
| ២៤.លោកស្រី | Lauren Tuohy | Australia Embassy |
| ២៥.លោកស្រី | KIM LAMB | Australia Embassy |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ឯកសារទី ២

លេខ.................................

**សូមគោរពជូន**

**សមាសភាពតំណាងក្រសួង ស្ថាប័ន ចូលរួមប្រជុំពិភាក្សា**

**លើករណីធ្វើអន្តរាគមន៍ នៃអំពើពពោះ**

ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ០៩:៣០នាទី ព្រឹក

នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

១/ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
២/ តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
៣/ តំណាងក្រសួងកិច្ចការនារី
៤/ តំណាងក្រសួងសុខាភិបាល
៥/ តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ
៦/តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍
៧/តំណាងអគ្គនាយដ្ឋានអត្តសញ្ញាណកម្ម
៨/ លោកវរសេនីយ៍ឯក **កែវ ធា** នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជនស្នងការដ្ឋានរាជធានីភ្នំពេញ
៩/ លោក **សេង ហៀង** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
១០/លោក **រស់ ពិសិដ្ឋ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៦
ប្រធានលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខ: ..........................

សន្លឹកទី ៣

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សាលើករណីបទអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ
## សាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីម្ភៃ វេលាម៉ោងប្រាំបួន និងសាមសិបនាទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) មានបើកកិច្ចប្រជុំពិភាក្សាលើ បទអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីអង្គភាពពាក់ព័ន្ធមួយចំនួន៖

| | | |
|---|---|---|
| ១.ឯកឧត្តម ឧ.ឯ | **ថោង សំអាត** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ២.ឯកឧត្តម ឧ.ឯ | **យឹម វិរៈ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៣.លោក ឧ.ត្រី | **លី ឡាយ** | អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ |
| ៤.លោក ឧ.ទោ | **ម៉ុក ប៊ុនឈាង** | អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ |
| ៥.លោកស្រី វ.ឯក | **អ៊ិត គន្ធា** | អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ |
| ៦.លោក | **យឹម សំអុល** | អនុប្រធាននាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៧.លោក វ.ឯក | **ជាន វុធ** | ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ |
| ៨.លោក វ.ឯក | **កែវ ជា** | ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ |
| ៩.លោក | **សាយ ស៊ីថា** | សមាជិកក្រុមប្រឹក្សានីតិកម្ម |

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម លោក លោកស្រី តំណាងឲ្យអង្គភាពពាក់ព័ន្ធ ដែលបានចូលរួមក្នុងកិច្ចប្រជុំពិភាក្សានាពេលនេះ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា៖ ចំពោះករណីដែលយើងបានធ្វើការបង្រ្កាបកន្លងមកខាងអូស្ត្រាលី គេបានឆ្លើយជាមួយយើងថា នេះជារឿងរបស់បុគ្គល(ឯកជន)។ ចំពោះជនសង្ស័យ ថមី ដែលជាស្ត្រីជនជាតិអូស្ត្រាលីនោះ គឺគេពុំទាន់បានឆ្លើយបំភ្លឺឲ្យបានអស់ចំពោះរឿងដែលខ្លួន

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សូមគោរពជូន

## សមាសភាពតំណាងក្រសួង ស្ថាប័ន ចូលរួមប្រជុំពិភាក្សា

## លើករណី "អន្តរការីរវាងអ្នកសុំកូន និងស្ត្រីពពោះ"

ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ០៩:៣០នាទី ព្រឹក

នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

| | |
|---|---|
| ១/ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | |
| ២/ តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ០១រូប |
| ៣/ តំណាងក្រសួងយុត្តិធម៌ | ០១រូប |
| ៤/ តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ | ០២រូប |
| ៥/ តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | ០២រូប |
| ៦/ តំណាងអគ្គនាយដ្ឋានអត្តសញ្ញាណកម្ម | ០២រូប |
| ៧/ តំណាងក្រុមប្រឹក្សានីតិកម្ម | ០១រូប |
| ៨/ លោកវរសេនីយ៍ឯក **កែវ ធា** តំណាងស្នងការដ្ឋានរាជធានីភ្នំពេញ | |